ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង ៖ ០៤១/២១ - ជារ៉ុងព្រីនធីង & អ៊ឹមប្រយឌើរី ខូអិលធីឌី**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គឹមស៊ាន**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ជារ៉ុងព្រីនធីង & អ៊ឹមប្រយឌើរី ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិត្រយឹង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៣៨២ ៣៤១ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក Louy Lin | ជំនួយការនាយកក្រុមហ៊ុន |
| ២- លោក ចឹក បឿន | រដ្ឋបាល |
| ៣- លោក តោ ដារ៉ាវិទ្ធ | មន្ត្រីផ្នែកច្បាប់សមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) |
| ៤- លោក ស្វាយ សារ៉េន | មន្ត្រីសុវត្ថិភាព |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ជារ៉ុងព្រីនធីង & អ៊ឹមប្រយឌើរី ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិត្រយឹង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៨៧ ៤២ ២៧ ៥៥ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនបងប្អូនកម្មករដែលចូលរួមធ្វើកូដកម្មនៅថ្ងៃទី១៣, ១៤, ១៥ ខែធ្នូ ឆ្នាំ២០២១។ មូលហេតុ ក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារឈ្មោះ យ៉យ យ័ន្ត ផ្នែកចម្រោះទឹកកខ្វក់ និងថតពុម្ព ផ្អែកតាមច្បាប់ស្តីពីការងារ។ ភាគីក្រុមហ៊ុនមិនឯកភាព សូមអនុវត្តតាមច្បាប់ស្តីពីការងារ។ ចំពោះកម្មករឈ្មោះ យ៉យ យ័ន្ត ជាវិវាទបុគ្គល ក្រុមហ៊ុនបានដោះស្រាយតាមច្បាប់ស្តីពីការងាររួចរាល់ហើយ។

២- ស្នើសុំបញ្ឈប់លោក LOUY LIN តួនាទីជាអ្នកគ្រប់គ្រងក្រុមហ៊ុនពីការងារ។ ភាគីក្រុមហ៊ុនមិនឯកភាព។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០(អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើង ស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីពីលទ្ធផលនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយឌើរី ខូអិលធីឌី លេខ ២៩១/២១ ក.ប/កណ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការ-ដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលការផ្តល់ដំណឹងពីនិយោជកនៃក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយឌើរី ស្តីពីការធ្វើកូដកម្មរបស់កម្មករនិយោជិតទាមទារ ឱ្យនិយោជកដោះស្រាយវិវាទការងារចំនួន ២ចំណុច។ បន្ទាប់ពីទទួលដំណឹងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញចុះទៅសម្របសម្រួលដល់ទីតាំងក្រុមហ៊ុន នៅថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជាចំនួន ២ចំណុច ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយឌើរី ខូអិលធី លេខ ២៩១/២១ ក.ប/ក.ណ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ២ចំណុចនេះ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទីរសៀល តាមរយៈលិខិតអញ្ជើញលេខ ២៥៣ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ទៅភាគីនិយោជក និងលិខិតអញ្ជើញលេខ ២៥៤ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ទៅភាគីកម្មករនិយោជិត ដោយភាគីទាំងពីរបានឆ្លើយតបតាមរយៈទូរសព្ទពីការទទួលបានការអញ្ជើញនេះ។

នៅព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតបានដាក់លិខិតជូនព័ត៌មាន និងស្នើសុំបញ្ចប់វិវាទ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការមិនចូលរួមនីតិវិធីសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយបញ្ជាក់ថា វិវាទនេះបានបញ្ចប់តាំងពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ និងស្នើឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ចប់វិវាទនៅក្នុងសំណុំរឿងលេខ ០៤១/២១ នេះ។ នៅថ្ងៃសវនាការ វេលាម៉ោង ១៤ និង ០០នាទី រសៀល ភាគីនិយោជកមានវត្តមាន តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដោយឡែក ភាគីកម្មករនិយោជិតមិនមានវត្តមាននៅថ្ងៃសវនាការតាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់លោក YANG CHIN YANG ជានាយកក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយឌើរី ខូអិលធីឌី ស្តីពីការប្រគល់សិទ្ធិជូនលោកស្រី LIN MING CHE, លោក ចឹក បឿន, លោក ស្វាយ សារ៉េន ជាជំនួយការនាយកក្រុមហ៊ុន, មន្ត្រីផ្នែកធនធានមនុស្ស, អ្នកអនុវត្តច្បាប់ ដើម្បីចូលរួមដោះស្រាយវិវាទការងាររួម នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។

២- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់លោក YANG CHIN YANG ជានាយកក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយឌើរី ខូអិលធីឌី ស្តីពីការប្រគល់សិទ្ធិជូនលោក គិម ពេជ្រដា និង លោក តោ ដារ៉ារិទ្ធ ជាប្រធានផ្នែកច្បាប់ GMAC, មន្ត្រីផ្នែកច្បាប់ GMAC ដើម្បីចូលរួមដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ចុះថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់ថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយឌើរី ខូអិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការជូនព័ត៌មានអំពីវិវាទនៃក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយឌើរី ខូអិលធីឌី និង ស្នើបញ្ចប់វិវាទ។

THE ARBITRATION COUNCIL

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយដើរី ខូអិលធីឌី លេខ ២៩១/២១ ក.ប/កណ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយដើរី ខូអិលធីឌី ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ដារ៉ុងព្រីនធីង & អ៊ីមប្រយដើរី ខូអិលធីឌី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ២៥៣ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ២៥៤ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាលទេ ដោយសារភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងមិនបានចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមការអញ្ជើញ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរឬទេ ក្នុងករណីភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងអវត្តមាននៅថ្ងៃសវនាការ?

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ក្រុមអាជ្ញាកណ្តាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត"*។

ប្រការ ២០ នៃប្រកាសដដែលនេះ ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"*។

ប្រការ ២១ នៃប្រកាសដដែលនេះ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់"*។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណា*

THE ARBITRATION COUNCIL

*មួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល" នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ដែលបានលើកឡើងខាងលើនេះមានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួន និងមិនចូលរួមសវនាការ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៦/០៧-ឡូទូសតិ៍, លេខ ២៧/០៧-អ៊ឹម និង វ៉េ ៣, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជូន តិចថាយល៍, លេខ ១៣១/១២-ម៉ាស្ទ័រ & ហ្វ្រៃង, លេខ ១០៨/១៣-អាត់តូ និងលេខ ៣៣២/ ១៤-ជី & ខេ ហ្គាមេន)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតមិនមានវត្តមាននៅក្នុងសវនាការអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី រសៀល តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញា-កណ្តាលនោះទេ ដោយនៅព្រឹកថ្ងៃសវនាការដដែលនេះ ភាគីកម្មករនិយោជិតបានដាក់លិខិតជូនព័ត៌មាន និងស្នើសុំបញ្ចប់វិវាទ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការមិនចូលរួមនីតិវិធីសវនា-ការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយបញ្ជាក់ថា វិវាទនេះបានបញ្ចប់តាំងពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ និងស្នើឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ចប់វិវាទនៅក្នុងសំណុំរឿងលេខ ០៤១/២១ នេះ។ ដូចនេះ យោងតាមអវត្តមានរបស់កម្មករនិយោជិត និងលិខិតជូនព័ត៌មាន និងស្នើសុំបញ្ចប់វិវាទខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅក្នុងសំណុំរឿងលេខ ០៤១/២១-ដារ៉ុងព្រីនធីង & អ៊ឹមប្រយរឌើរី ខូអិលធីឌី មិនមានវិវាទសម្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាទៀតនោះទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៤១/២១-ដារ៉ុងព្រីនធីង & អ៊ឹមប្រយរឌើរី ខូអិលធីឌី នេះ។

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្តាល នៃសំណុំរឿងលេខ ០៤១/២១-ដារ៉ុងព្រីនធីង & អ៊ឹមប្រយរឌើរី ខូអិលធីឌី។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំខ សុទ្ធី**

ហត្ថលេខា ៖ ----------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖
ឈ្មោះ ៖ **ស៊ីន គីមស៊ាន**
ហត្ថលេខា ៖-----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖
ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**
ហត្ថលេខា ៖ -----------------------------